## ឯកឧត្តម ទេសរដ្ឋមន្ត្រី ចម ប្រសិទ្ធ ជួបប្រធានអគ្គនាយកក្រុមហ៊ុន **SAMMITR Green Power Co,Ltd**



នៅរសៀលថ្ងៃទី៣១ ខែ សីហា ឆ្នាំ២០១៥ ឯកឧត្តម ចម ប្រសិទ្ធ ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម និងសិប្បកម្ម បានទទួលជួបលោក **Surayut Posirisuk** ប្រធានអគ្គនាយកក្រុមហ៊ុន **SAMMITR Green Power Co,Ltd** និងសហការី ដើម្បីពិភាក្សាការងារនៅទីស្តីការក្រសួង ។



ក្នុងជំនួបពិភាក្សានោះ លោក **Surayut Posirisuk** បានជម្រាបពីជោគជ័យរបស់ក្រុមហ៊ុនរយៈពេលជិត៥០ ឆ្នាំកន្លងទៅនេះ ទៅលើការងារផលិតរថយន្ត និងផលិតគ្រឿងបន្លាស់រថយន្តខ្នាតដឹក និងសណ្តោង ហើយជាបន្តបន្ទាប់ក្រុមហ៊ុនបានពង្រីកខ្លួន ដោយបានទទួលទំនុកចិត្តពីអតិថិជន និងផ្នែកឧស្សាហកម្មរថយន្ត នៃបណ្តាប្រទេសមួយចំនួន ដោយនៅឆ្នាំ១៩៩២ ក្រុមហ៊ុនបានចុះកិច្ចព្រមព្រៀងចងសម្ព័ន្ធអាជីវកម្មជាមួយក្រុមហ៊ុន **FAW** និងក្រុមហ៊ុន **FAW-VOLKSWAGEN Group** នៅប្រទេសចិន ដើម្បីផលិតគ្រឿងបន្លាស់រថយន្តផ្គត់ផ្គង់ដល់ក្រុមហ៊ុនរោងចក្រទាំងពីរខាងលើ ជាពិសេស គឺតម្លើងប្រព័ន្ធផ្លាស់ប្តូររថយន្តសម្រាប់ប្រើប្រាស់ជាមួយ ហ្គាសធម្មជាតិ (Natural Gas)។ ជាក់ស្តែង នៅពេលថ្មីៗនេះ ក្រុមហ៊ុនទទួលបានទំនុកចិត្តថ្មីបន្ថែមទៀត គឺបានចុះកិច្ចព្រមព្រៀងជាមួយក្រុមហ៊ុន TOYOTA របស់ជប៉ុន ដើម្បីផ្គត់ផ្គង់គ្រឿងបន្លាស់

និងតម្លើងប្រព័ន្ធសម្រាប់រថយន្តប្រើប្រាស់ ហ្គាសធម្មជាតិ ពីព្រោះក្រុមហ៊ុន TOYOTA បច្ចុប្បន្ន ចាប់ផ្តើមផលិតទាំងរថយន្តប្រើសាំង ប្រើម៉ាស៊ូត និងប្រើហ្គាសធម្មជាតិ ក្នុងបរិបទដែលប្រេងសាំងលើទីផ្សារពិភពលោកមានការប្រែប្រួលឡើងចុះ និងមានតម្លៃថ្លៃ ។

ចំពោះគោលបំណងនៃជំនួបថ្ងៃនេះ លោកប្រធានអគ្គនាយកក្រុមហ៊ុន ចង់ពិនិត្យលទ្ធភាពលក់ផលិតផលរបស់ក្រុមហ៊ុននៅលើទីផ្សារកម្ពុជា រួមមានរថយន្ត និងគ្រឿងបន្លាស់ជាដើម ។ ក៏ប៉ុន្តែ ដំណាក់កាលដំបូង ក្រុមហ៊ុនរបស់លោកចង់បង្កើតស្ថានីយ៍ចាក់ហ្គាសធម្មជាតិតាមបណ្តោយផ្លូវ ដែលជាច្រករបៀងសេដ្ឋកិច្ចរបស់កម្ពុជា ដូចជាៈពីភ្នំពេញ ទៅខេត្ត ព្រះសីហនុជាដើម ។

ឯកឧត្តម ទេសរដ្ឋមន្ត្រី ចម ប្រសិទ្ធ បានសម្តែងការស្វាគមន៍ និងវាយតម្លៃខ្ពស់ចំពោះភាពជោគជ័យរបស់ក្រុមហ៊ុន ។ ឯកឧត្តមទេសរដ្ឋមន្ត្រី បានជម្រាបថាៈពិតជាស្របពេលល្អណាស់ ក្នុងដំណាក់កាលដែលតម្លៃប្រេងសាំងលើទីផ្សារពិភពលោក កំពុងមានការឡើងចុះ ។ ដូច្នេះការប្រើប្រាស់រថយន្តប្រើហ្គាសធម្មជាតិ ជាជម្រើសល្អមួយ បានជួយសន្សំសំចៃ ជាពិសេសបានជួយកាត់បន្ថយលើថ្លៃដឹកជញ្ជូនផងដែរ ។ ឯកឧត្តមទេសរដ្ឋមន្ត្រីបានបន្តថាៈ ជាការប្រសើរមួយដែលក្រុមហ៊ុន បានពិនិត្យលទ្ធភាពបង្កើតស្ថានីយ៍ចាក់ហ្គាសធម្មជាតិតាមបណ្តោយផ្លូវ ដែលជាច្រករបៀងសេដ្ឋកិច្ចរបស់កម្ពុជា ដូចជាៈផ្លូវពីភ្នំពេញទៅកាន់ ខេត្ត ព្រះសីហនុ និងពីភ្នំពេញ ទៅប៉ោយប៉ែត និងផ្លូវជាតិសំខាន់ៗដ៏ទៃទៀត។ ពីព្រោះ នៅកម្ពុជាបច្ចុប្បន្នមានស្ថានីយ៍ចាក់ហ្គាសមិនច្រើនទេ ស្របដែលអ្នកប្រើប្រាស់រថយន្តប្រើហ្គាសមាននិន្នាការកើនឡើង ។ ឯកឧត្តមទេស រដ្ឋមន្ត្រី បានបញ្ជាក់បន្ថែមថាៈ បើមានស្ថានីយ៍ចាក់ហ្គាសធម្មជាតិច្រើនហើយ ការនាំចូលរថយន្តប្រើហ្គាស រឺគ្រឿងបន្លាស់មកចែកចាយលើទីផ្សារកម្ពុជា ក៏មានភាពងាយស្រួល និងទទួលបានការគាំទ្រពីអតិថិជនផងដែរ ។

